# ព្រះសឡដីកា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## វត្តខ្មែរកាណាដា នៅក្នុងវេបសាយ

**www.hoksavannn.org**

១- <u>អំពីគោលបំណងនៃការបង្កើតវេបសាយ</u> ៖

ការបង្កើតវេបសាយនេះឡើង ក្នុងគោលបំណងរួមវិភាគទានដ៏ស្ទួចស្ទើង ជួយអភិវឌ្ឍន៍សីលធម៌ឲ្យខ្ពស់ឡើងវិញ បន្ទាប់ពីបានត្រូវចុះខ្សោយរវាង២០, ៣០ឆ្នាំកន្លងមកនេះ ដោយសារទាស់ទែងខ្វែងគំនិតគ្នា ។ ព្រមជាមួយគ្នានោះ ទុកជាការជួយពង្រឹងគ្រឹះនៃអត្តសញ្ញាណខ្មែរឲ្យរឹងមាំឡើងវិញ ទប់ទល់នឹងវប្បធម៌បរទេស ដែលចូលជ្រៀតជ្រែកប្រទេសកម្ពុជាកាន់តែខ្លាំងឡើងៗ ។ គោលគំនិតបញ្ចេញទស្សនៈទាំងអស់នេះ ផ្អែកទៅលើគោលការណ៍ព្រះពុទ្ធសាសនា យោងទៅតាមប្រជាពលរដ្ឋខ្មែរច្រើនលើសលប់គោរពព្រះពុទ្ធសាសនា ទុកព្រះពុទ្ធសាសនាជាមាគ៌ាប្រចាំជីវិតរបស់ខ្លួន ។ នៅក្នុងវេបសាយនេះ ក្រៅពីគោលទស្សនៈព្រះពុទ្ធសាសនា នឹងដកស្រង់យកគោលគំនិតល្អៗរបស់ចាស់បូរាណខ្មែរ ដែលដាស់តឿនកូនចៅខ្មែរ ឲ្យចេះរស់នៅប្រកបដោយសុខដុមរមនា ជាមួយគ្នាក្នុងគ្រួសារនិងក្នុងសង្គមជាតិរបស់ខ្លួន ដែលក្លាយជាទំនៀមទំលាប់ប្រពៃណីរហូតមកដល់សព្វថ្ងៃនេះ ។ ក្រៅពីនោះ នឹងឲ្យយោបល់ដល់នយោបាយខ្មែរទាំងអស់ ក្នុងន័យស្ថាបនា ពុំមែនស្អប់ខ្ពើមគណបក្សនយោបាយណាមួយ ហើយក៏ពុំនៅក្រោមអំណាចគណបក្សនយោបាយណាមួយក្នុងការធ្វើរណបឡើយ ។ ការបញ្ចេញទស្សនៈជាមួយនឹងការរិះគន់ក្នុងន័យស្ថាបនា ពិតជាមានការប៉ះទង្គិចទៅលើអ្នកនយោបាយខ្លះ ដែលមើលទៅឃើញថា ដឹកនាំខ្មែរទៅរកសេចក្តីវិនាស ខូចប្រយោជន៍ ខូចកិត្តិយសជាតិ និងនាំឲ្យខ្មែរបែកបាក់គ្នា ។ ដូចមានបញ្ជាក់លើកមុនមកហើយថា ព្រះសង្ឃអាចឲ្យយោបល់ អាចណែនាំអ្នកនយោបាយទៅរកផ្លូវល្អ ផ្លូវត្រូវ តាមផ្លូវធម៌អាចបាន គ្មានទាស់ខុសនឹងវិន័យរបស់ព្រះពុទ្ធសាសនាឡើយ ព្រោះសកម្មភាពនេះ ព្រះពុទ្ធបានទេសនាណែនាំព្រះបាទពិម្ពិសារ, ព្រះបាទបសេនទិកោសលជាដើម ដែលសុទ្ធសឹងជាព្រះមហាក្សត្រកាន់ការនយោបាយដឹកនាំស្រុកទេស ឲ្យមានទសពិធរាជធម៌ ដឹកនាំស្រុកទេសឲ្យមានសន្តិភាពនិងលូតលាស់ចំរើន ពុំគួរទុកព្រះសង្ឃឲ្យដាច់ចេញពីសង្គមទេ ព្រោះព្រះសង្ឃក៏ជាធនធានមនុស្សយ៉ាងឧត្តុងឧត្តម សំរាប់ជួយសង្គមខ្មែរ ឲ្យមានវឌ្ឍនភាពជាពិសេសវឌ្ឍនភាពខាងសីលធម៌ ។ ដូច្នេះអ្នកនយោបាយណាដែលត្រូវការរិះគន់ ពុំគួរអាក់អន់ចិត្តទេ គួរតែពិនិត្យមើលខ្លួនឯងវិញ តើមានប្រឡាក់ប្រឡូសដូចគេរិះគន់ឬទេ ? បើមានដូចនេះមែន ត្រូវតែកែកំហុសនោះ បើកែឲ្យត្រូវវិញហើយ ខ្លួននឹងបានល្អវិញ ដោយសារការបានពន្លឺពីពាក្យរិះគន់នោះ ។ លោកអ្នកសប្បុរសទុកអ្នករិះគន់ជាគ្រូ បើពាក្យរិះគន់នោះមានសច្ចធម៌ ហើយអ្នករិះគន់នោះជាជនសប្បុរសដែរ មានគំនិតបរិសុទ្ធនិងប្រកបដោយវិចារណញ្ញាណ ។ កុំទុកអ្នករិះគន់ជាសត្រូវ តែត្រូវទុកជាពន្លឺសំរាប់បំភ្លឺខ្លួនវិញ ។ ការមិនទទួលពាក្យរិះគន់យកមកពិចារណា ថែមទាំងចោទអ្នករិះគន់វិញ ឬរហូតដល់ប្រើអំពើហឹង្សា មានលួចធ្វើឃាតជាដើម ទំរើបែបនេះពុំមែនជាអំពើល្អសំរាប់ធ្វើឲ្យសង្គមលូតលាស់ចំរើនក្នុងអារ្យប្រទេសដែលមានសីលធម៌ទេ តែជាអំពើអាក្រក់ដែលនាំឲ្យខ្លួននិងប្រទេសវិនាសអន្តរាយវិញទេ ។ គួរទុកអ្នកហៃអើដែលពុំហ៊ាននិយាយអំពីកំហុសអ្នកដឹកនាំ ជាសត្រូវវិញទើបត្រឹមត្រូវ ព្រោះអ្នកហៃអើដែលតែងតែបញ្ជោរអ្នកដឹកនាំនេះឯង ដែលធ្វើឲ្យអ្នកដឹកនាំទទួលគ្រោះថ្នាក់ រហូតអស់បុណ្យស័ក្តិ ព្រោះពុំដឹងការពិតដើម្បីកែខ្លួន។ លោកអ្នកសប្បុរសប្រណាំងប្រជែងយកឈ្នះចាញ់គ្នា ដោយការសាងសេចក្តីល្អ ។ បានសេចក្តីថា ជនណាបានសាងសេចក្តីល្អបានច្រើន ជននោះជាអ្នកឈ្នះ ។ គួរទុកការរិះគន់ដូចជាឪពុកម្តាយអប់រំកូន ព្រោះធម្មតាឪពុកម្តាយប្រៀនប្រដៅកូន មានពាក្យធំពាក្យតូច រហូតស្តីថាខ្លះ ក៏ក្នុងគោលបំណងឲ្យកូនបានល្អ កុំឲ្យកូនមានទុក្ខ ។ យ៉ាងណាមិញ ប្រជាពលរដ្ឋខ្មែរបច្ចុប្បន្ននេះត្រូវការជាចាំបាច់ នូវចំណេះដឹងគ្រប់យ៉ាង មានចំណេះខាងសីលធម៌នេះឯង ដើម្បីឲ្យខ្លួនមានគុណសម្បត្តិសំរាប់កសាងសង្គមឲ្យបានចំរើនលូតលាស់ ។ សីលធម៌ជាគុណធម៌របស់មនុស្សគ្រប់វ័យគ្រប់ភេទគ្រប់ឋានៈ ។ មនុស្សចេះដឹងច្រើនយ៉ាងណាក៏ដោយ មានទ្រព្យសម្បត្តិច្រើនយ៉ាងណាក៏ដោយ បើខ្វះសីលធម៌ហើយ នឹងទៅជាមនុស្សថោកទាប ជាមនុស្សគ្មានតម្លៃក្នុងសង្គម ជាមនុស្សត្រូវសង្គមច្រានចោល ពុំរាប់អាន ជាមនុស្សសត្រូវរបស់សង្គម ព្រោះថាបើគ្មានសីលធម៌ហើយ មនុស្សនោះតែងតែបៀតបៀនធ្វើបាបអ្នកដទៃ ។ ក្នុងន័យនេះ អ្នកដែលធ្លាប់ប្រព្រឹត្តអាក្រក់កាប់សម្លាប់គេ តាំងពីសម័យខ្មែរក្រហមមក ល្មមទុកអំពើអាក្រក់នេះជាមេរៀន ដោយឈប់កាប់សម្លាប់គេតទៅទៀត ទោះបីសម្លាប់ដោយផ្លូវនយោបាយក្តី ពុំមែននយោបាយក្តី ព្រោះថាបើអំពើនេះបើចេះតែប្រព្រឹត្តទៅមុខទៀត ជាតិសាសន៍ខ្មែរនឹងត្រូវវិនាស ។ បើធ្វើពុំបានដូចសម័យមហានគរ ដែលអ្នកប្រវត្តិសាស្ត្រចាត់ទុកជាសម័យដ៏រុងរឿង ដែលជះឥទ្ធិពលទៅលើប្រទេសជិតខាងផងនោះ ក៏គួរធ្វើយ៉ាងណាឲ្យប្រទេសកម្ពុជាបច្ចុប្បន្ន ដែលនៅសេសសល់ទឹកដីដ៏តូចនេះ នៅជាប្រទេសឯករាជ្យ និងថែរក្សាបូរណភាពទឹកដីឲ្យគង់វង់នៅក្នុងផែនទីពិភពលោក ។ ជនជាតិកម្ពុជាគ្រប់រូបគប្បីគិតថា ទាំងអស់គ្នាជាជាតិខ្មែរ មានវប្បធម៌ ភាសា សាសនាដូចគ្នានៅលើទឹកដីដូនតារបស់ខ្លួន ទោះបីជនជាតិខ្មែរខ្លះមករស់នៅបរទេសក៏ដោយ ក៏គួរនាំគ្នាសងគុណប្រទេសរបស់ខ្លួន ដោយរកមធ្យោបាយគ្រប់បែបយ៉ាងរក្សាការពារប្រទេសកម្ពុជា ឲ្យបានស្ថិតនៅគង់វង់ ព្រោះប្រទេសកម្ពុជាជាកម្មសិទ្ធិរបស់ជនជាតិខ្មែរគ្រប់រូប ពុំមែនជាកម្មសិទ្ធិដាច់មុខរបស់ជនជាតិខ្មែរណាតែមួយក្រុម រហូតប្រើលទ្ធិផ្តាច់ការទៅលើខ្មែរដទៃទៀតឡើយ ។ កុំធ្វើឲ្យខូចប្រយោជន៍ជាតិ តែត្រូវចាត់ទុកប្រយោជន៍ជាតិជាធំជាងប្រយោជន៍ផ្ទាល់ខ្លួននិងប្រយោជន៍បក្សពួក ហើយក៏មិនត្រូវបំរើបរទេស ដោយសារតែការពារប្រយោជន៍ផ្ទាល់ខ្លួននិងប្រយោជន៍បក្សពួកឡើយ ។ នេះជាគោលគំនិតខ្លះនៅក្នុងវេបសាយ ចាត់ទុកជាការបបួលជនរួមជាតិខ្មែរគ្រប់រូប នៅក្នុងនិងក្រៅប្រទេស ជួយស្រោចស្រង់ប្រទេសកម្ពុជាជាមាតុភូមិ ដែលកំពុងមានវិបត្តិនេះ ឲ្យឆ្លងផុតដល់ត្រើយសុខសាន្តដោយសុវត្ថិភាព ។ វេបសាយនេះ គឺជាវិភាគទានដ៏តូច ឆ្លៀតធ្វើក្នុងពេលដ៏មមាញឹកក្នុងកិច្ចការដទៃទៀត បានអាយុប៉ុន្មានទៅតាមលទ្ធភាព។

២- <u>អ្នកនយោបាយខ្មែរគិតប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍បក្សពួក ជាងប្រយោជន៍ជាតិ</u> ៖

ការជាប់គាំងនយោបាយអស់រយៈកាលមួយឆ្នាំពុំអាចបង្កើតរដ្ឋាភិបាលបាន មកអំពីមហិច្ឆិតាឥតព្រំដែនរបស់គណបក្សដែលធ្លាប់កាន់អំណាច ពុំព្រមអនុវត្តតាមរដ្ឋធម្មនុញ្ញកម្ពុជាដែលមានក្នុងបច្ចុប្បន្ន ព្រោះខ្លាច

សភាពុំអនុម័តឲ្យខ្លួនឡើងកាន់អំណាចតទៅទៀត ក៏បង្កើតរដ្ឋធម្មនុញ្ញ
បន្ថែមថ្មីមួយទៀត ដើម្បីឲ្យមានការបោះឆ្នោតជាកញ្ចប់ គឺបោះឆ្នោតរួមគ្នា
ទាំងរចនាសម្ព័ន្ធសភានិងរចនាសម្ព័ន្ធរដ្ឋាភិបាល ដោយវិធីលើកដៃ ដោ
យព្យួរទុករដ្ឋធម្មនុញ្ញចាស់ត្រង់ចំណុចនេះ ។ មតិទូទៅបានចោទថា ទំរើ
បែបនេះជាការធ្វើរដ្ឋប្រហាររដ្ឋធម្មនុញ្ញ ជាអំពើផ្ដាច់ការតាមរបៀបកុម្មុយ
និស្ត ។ ប៉ុន្តែរដ្ឋាភិបាលថ្មីនេះបានដោះស្រាយថា គេធ្វើស្របច្បាប់ តាម
ការចាំបាច់របស់ជាតិ ។ ត្រង់នេះទុកឲ្យប្រជាពលរដ្ឋខ្មែរវិនិច្ឆ័យចុះ ។ គ
ណបក្សមួយទៀតផ្សំគំនិតនិងចូលរួមក្នុងការបោះឆ្នោតជាកញ្ចប់ដោយ
លើកដៃនេះ មកអំពីនិស្ស័យត្រូវគ្នា បានប្រយោជន៍រួមគ្នា បានជារត់រក
គ្នា ដូច្នេះការទទួលខុសត្រូវក៏ត្រូវទទួលរួមគ្នាដែរ ។ ចំពោះព្រះមហាក្ស
ត្រខ្មែរ បើពិនិត្យមើលតាមអាការៈ ម្ដងគង់ព្យុងយ៉ាង ម្ដងគង់ប៉េកាំង ម្ដ
ងថាដាក់រាជ្យ ម្ដងថានិរទេសរហូតបើមិនបានឲ្យដាក់រាជ្យទេ ម្ដងថាទៅ
គង់នៅសៀមរាប ឥឡូវនេះដំណឹងចុងក្រោយថា ព្រះអង្គនឹងយាងត្រ-
ឡប់មកកម្ពុជាវិញដោយគ្មានលក្ខខណ្ឌ ។ បើពិនិត្យតាមអាកប្បកិរិយា
របស់ព្រះអង្គ ជាមួយនឹងសារលិខិតខ្លះក្នុងវេបសាយ ហាក់ដូចជាព្រះ
អង្គប្រឆាំងនឹងការបោះឆ្នោតជាកញ្ចប់នេះ ប៉ុន្តែបើគេពិនិត្យមើលសកម្ម
ភាពរបស់ព្រះអង្គវិញ គេឥតមានសង្ស័យទៀតទេ គឺព្រះអង្គពិតជាគាំទ្រ
ការបោះឆ្នោតជាកញ្ចប់នេះ ព្រោះព្រះអង្គបានឡាយព្រះហស្ថលេខាលើ
ក្រឹត្យជាបន្តបន្ទាប់គ្នា រហូតដល់តែងតាំងរដ្ឋាភិបាលថ្មីនេះ មិនតែប៉ុ-
ណ្ណោះ បានបំពាក់ផ្កាយ៨ដល់ឧត្ដមសេនីយ៍ម្នាក់ ដែលបានចុះហត្ថលេ
ខាលើច្បាប់បោះឆ្នោតជាកញ្ចប់នោះថែមទៀត ។ សំនួរថា បើព្រះអង្គពុំ
គាំទ្រទេ ហេតុអ្វីបានជាចុះហត្ថលេខា ? ឬការចុះហត្ថលេខានេះ ដោយ
ការភ័យខ្លាចគ្មានផ្លូវជំរើស ? ឬដោយការមានផ្នូរអ្វីមួយមកវិញ ? ត្រង់
នេះគ្មានប្រភពណាបញ្ជាក់ច្បាស់ទេ បើដឹងការពិតនេះ ក៏ពុំហ៊ាននិយាយ
ដែរ ។

តាមភស្ដុតាងទាំងអស់ខាងលើនេះបញ្ជាក់ថា អ្នកនយោបាយខ្មែរ
តាំងពីថ្នាក់លើរហូតថ្នាក់ក្រោម គិតតែប្រយោជន៍ផ្ទាល់ខ្លួននិងបក្សពួក
ដោយទុកប្រយោជន៍ជាតិនៅជ្រុងម្ខាង ។ បើដោះស្រាយប្រយោជន៍ផ្ទា-
ល់ខ្លួននិងបក្សពួកមិនបានទេ ប្រយោជន៍ជាតិក៏ដោះស្រាយពុំរួចដែរ ដោ
យទុកប្រយោជន៍ផ្ទាល់ខ្លួននិងប្រយោជន៍បក្សពួក ជាអទិភាពដែលត្រូវ
ដោះស្រាយមុនគេ ។ ភស្ដុតាងដែលឥតប្រកែកបាន បន្ថែមលើភស្ដុតាង
ខ្លះទៀត គឺឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និង
អនុរដ្ឋលេខាធិការ មានគ្នាជាង៣០០នាក់ ច្រើនជាងគេលើពិភពលោក
បើគិតពីប្រជាពលរដ្ឋខ្មែរដែលមានចំនួនតែជាង១០លាននាក់ ។ បានសេ
ចក្ដីថា គេបង្កើនចំនួនបុគ្គលិកនិងបង្កើតមុខក្រសួងបន្ថែម ដើម្បីរកការ
ឲ្យបក្សជនធ្វើ អ្នកធ្វើការចាស់ទុកនៅដដែល ហើយផ្ដល់មុខងារឲ្យអ្នក
ធ្វើការថ្មី យកចិត្តបក្សជន ដើម្បីកុំឲ្យបែកចេញពីបក្ស ។ ដូច្នេះត្រូវចំណា
យថវិកាបន្ថែម ទន្ទឹមគ្នានឹងគ្រូបង្រៀនដែលមានប្រាក់បៀវត្សតិចតួច ដែ
លមិនអាចទ្រទ្រង់គ្រួសារបាន រដ្ឋាភិបាលឆ្លើយតបទៅគ្រូបង្រៀនដែល
សុំតម្លើងប្រាក់ខែ ថាគ្មានថវិកា ។

ក្នុងគម្ពីរធម្មបទនៃព្រះពុទ្ធសាសនានិយាយថា ជនណាលោភលាភ
សក្ការៈ, លាភសក្ការៈនោះសម្លាប់ជននោះវិញ ។ សូមរដ្ឋាភិបាលអាណត្តិ
ទីបី ដែលត្រូវគេចោទថាជារដ្ឋាភិបាលខុសច្បាប់នេះ ទទួលខុសត្រូវចំ-
ពោះមុខប្រជាពលរដ្ឋខ្មែរ ចំពោះផលវិបាកអាក្រក់ណាមួយទៅអនាគត
ទៀត ដូចជាបញ្ហាភាពក្រីក្រនៃប្រជាពលរដ្ឋ, អំពើពុករលួយ, បញ្ហាបូរ-
ណភាពទឹកដី, បញ្ហាហូរចូលនៃអន្តោប្រវេសន៍ខុសច្បាប់, បញ្ហាការកើន
ឡើងនៃអំពើហឹង្សា និងការកើនឡើងនៃអំពើអបាយមុខ ។ បញ្ហាទាំង
អស់នេះ បើគេដោះស្រាយតាមរបៀបព្រះពុទ្ធសាសនា អាចដោះស្រាយ
រួច គឺព្រះពុទ្ធឲ្យមនុស្សគ្រប់រូប គិតពីប្រយោជន៍ខ្លួនហើយ ប៉ុន្តែកុំឲ្យខូច
ប្រយោជន៍សង្គមដោយសារប្រយោជន៍ខ្លួន ហើយត្រូវអនុវត្តតាមនាយ-
កធម៌ គឺត្រូវបំពេញមុខនាទីជាអ្នកដឹកនាំឲ្យបានល្អ ។

៣- <u>អំពីអំពើហឹង្សានៅប្រទេសកម្ពុជា</u> ៖

អំពើហឹង្សានៅតែកើតមានជាបន្តនៅប្រទេសកម្ពុជា ។ តាមអ្នកស-
ង្កេតការណ៍បានថ្លែងថា អំពើហឹង្សាខ្លះកើតអំពីអំពើហឹង្សានយោបាយ។
អំពើហឹង្សាដោយការចងគំនុំ ជាអំពើហឹង្សាធម្មតា ដែលគេពុំអាចកំចាត់
ឲ្យអស់បាន ព្រោះមនុស្សនៅមានលោភៈ ទោសៈ មោហៈ ប៉ុន្តែបើបាន
អប់រំតាមវិធីព្រះពុទ្ធសាសនា ឲ្យឃើញទោសពៃរ៍នៃការប្រព្រឹត្តអំពើហឹ-
ង្សា ហើយឲ្យមានមេត្តាធម៌ អាចបន្ថយអំពើហឹង្សានេះបាន ។ ចំណែកអំ
ពើហឹង្សាតាមផ្លូវនយោបាយវិញ មានគ្រោះថ្នាក់ធ្ងន់ណាស់ដល់ជាតិ
ព្រោះជាអំពើចាត់ចែងជាខ្សែសង្វាក់ មានលក្ខណៈទ្រង់ទ្រាយធំឬតូចទៅ
តាមគំរោងការនៃអ្នកនយោបាយ ដូចពួកខ្មែរក្រហមបានចេញផែនការ
ដាក់ទិសដល់កម្មាភិបាលរបស់ខ្លួន ឲ្យសម្លាប់ទាហានរបស់លោកលន់-
នល់ទាំងអស់នៅប្រទេសកម្ពុជាទាំងមូល ។ ចំពោះអំពើហឹង្សានៅប្រទេ
សកម្ពុជាតាំងពី១០, ២០ឆ្នាំរហូតបច្ចុប្បន្ន អ្នកសង្កេតការណ៍សង្ស័យថា
ជាហឹង្សានយោបាយ ព្រោះអ្នកស្លាប់ដែលត្រូវគេធ្វើឃាតនោះ សុទ្ធតែ
បញ្ញវ័ន្ត, អ្នកមានប្រជាប្រិយ, អ្នកសារពត៌មាន និងបក្សប្រឆាំង ។ ព្រោះ
ធម្មតារបបផ្ដាច់ការតែងតែរិះរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីកុំឲ្យមា
នអ្នកប្រឆាំង ។ មធ្យោបាយនោះមានពីរយ៉ាង គឺទីមួយការលួងលោម
ទឹកចិត្តដោយឲ្យបុណ្យស័ក្តិ ដោយឲ្យដុល្លារ បើប្រុសដោយជួយរកប្រ-
ពន្ធ ឬរកស្រីកំណាន់ចិត្តឲ្យ ដើម្បីឲ្យបញ្ញវ័ន្តដែលមានប្រជាប្រិយភាព
នោះ បិទមាត់កុំឲ្យនិយាយអាក្រក់ ។ បើមធ្យោបាយទីមួយនេះមិនបាន
សំរេច គេប្រើមធ្យោបាយទីពីរ គឺការលួចធ្វើឃាតដោយអាថ៌កំបាំង ឬក៏
រកលេសចោទឲ្យស្របច្បាប់ ។ មូលហេតុចោទគឺជាលេសដែលគេបង្កើ
តឡើង ហើយបើប៉ូលិសកងអាវុធហត្ថតុលាការជារបស់គេទៀត ជន
ដែលត្រូវគេកំចាត់ដែលទិញក្បាលពុំបាននោះ ត្រូវជាប់ទោសដោយអយុ
ត្តិធម៌ ។ បើឥស្សរជនឬបញ្ញវ័ន្តដែលមានឧត្ដមគតិជាតិខ្ពស់បានត្រូវគេ
ធ្វើឃាត អាជ្ញាធរពុំដែលចាប់បានអ្នកប្រព្រឹត្តអំពើឧក្រិដ្ឋនោះឡើយ ។
ពេលគេរិះគន់ខ្លាំង ដើម្បីកុំឲ្យខូចនយោបាយ ហើយដើម្បីបំបិទដាន ក៏
ទៅចាប់អ្នកដែលគេបានជួលឲ្យមកឆ្លើយទទួលសារភាព ឬក៏ទៅចាប់អ្នក
ដែលឥតដឹងអ្វីនោះ មកកាត់ទោសជារបៀបសិប្បនិមិត្ត ។ ផ្ទុយទៅវិញ
បើឆាកល្ខោនណា ដែលគេរៀបចំទុករបៀបស្វាស៊ីបាយមកលាបមាត់
ពពែ អាជ្ញាធរចាប់បានភ្លាម គឺទៅចាប់អ្នកដែលគេតម្រូវឲ្យចាប់ គេចាប់
ឲ្យជននោះមានកំហុស ដើម្បីបំបិទមាត់ ។ នេះជាការពោលជាទូទៅចំ-
ពោះប្រទេសណាដែលមានរបបផ្ដាច់ការ ។ ចំពោះប្រទេសកម្ពុជា បើ
មានបែបនេះ គប្បីកំចាត់ចេញ បើពុំទាន់កើតមានទេ ត្រូវការពារកុំឲ្យកើត
មាន ។ ឯអ្នកស៊ីឈ្នួលសម្លាប់មនុស្ស ឬបំរើគេដាច់ថ្លៃ គេប្រើឲ្យធ្វើអ្វី
ចេះតែធ្វើតាមគេ គេឲ្យទៅសម្លាប់ ចេះតែទៅសម្លាប់ គប្បីគិតថា ថ្ងៃណា
មួយខ្លួនក៏ត្រូវគេសម្លាប់ អ្នកដែលសម្លាប់នោះគឺ ចៅហ្វាយដែលប្រើខ្លួន
នោះឯង បានជាគេសម្លាប់អ្នក ព្រោះដើម្បីបំបិទដាន ដើម្បីកុំឲ្យអ្នកឆ្លើយ
ដាក់ទេ ។ បើនិយាយតាមព្រះពុទ្ធសាសនា អំពើទាំងអស់នោះជាអំពើ
បាប នឹងបានទទួលផលបាបគឺសេចក្ដីទុក្ខ ដូច្នេះបើអ្នកចង់បានសុខក្នុង
លោកនេះនិងលោកខាងមុខ គប្បីវៀរចាកអំពើទាំងនេះ ។ ជនណាដែល
និយមការកាប់សម្លាប់ ត្រូវឈប់កុំជាន់ដានខ្មែរក្រហម បើទាំងអស់គ្នា
ដឹងថាខ្មែរក្រហមធ្វើខុស កុំធ្វើតាមខ្មែរក្រហមតទៅទៀត ។ ទាំងអស់គ្នា
គប្បីគិតតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធថា សម្លាប់គេដូចជាសម្លាប់
ខ្លួនឯង លួចកូនប្រពន្ធគេ ដូចលួចទ្រព្យសម្បត្តិខ្លួន ។ គួរឲ្យអាម៉ាស់បំផុ

ត ដែលប្រទេសជិតខាងពោលថាខ្មែរវាសម្លាប់តែគ្នាវា វាពូកែតែជាមួយខ្មែរគ្នាវា ប្រខាំគ្នាដូចឆ្កែ គេនិយាយទៅកាន់កូនគេដែលទូន្មានពុំបានថា នាងឯង-អ្នកឯងជាតិក្រោយ ឲ្យកើតជាខ្មែរ ព្រោះខ្មែរអាក្រក់ណាស់ តែខ្មែរគ្នាឯង បំបាត់អ្នកចេះដឹង ច្រណែនឈ្នានិសគ្នា សូម្បីកូនក្មេងគេនៅតូច ក៏ដឹងរឿងនេះដែរ ។

៤- <u>អំពីលក្ខណៈរបស់សម្ដេច ទេព-វង្ស</u> ៖

ក្នុងពេលថ្មីៗនេះ សម្ដេច ទេព-វង្ស បានធ្វើអន្តរាគមន៍ កុំឲ្យព្រះមហាក្សត្រខ្មែរដាក់រាជ្យ ។ តាមការសង្កេតសកម្មភាពរបស់សម្ដេច ទេព-វង្ស តាំងពីដើមរហូតមកទល់ពេលនេះ ពុំមែនកើតចេញពីគំនិតផ្ទាល់របស់សម្ដេច ទេព-វង្ស ឡើយ គឺកើតចេញមកពីគណបក្សមួយនៅពីក្រោយ គឺសម្ដេច ទេព-វង្ស ហាក់ដូចជាអ្នកនាំពាក្យឲ្យគណបក្សនោះប៉ុណ្ណោះ ព្រោះព្រះថេរដីការបស់សម្ដេច ទេព-វង្ស ដូចគ្នាបេះបិទនឹងសំដីរបស់អ្នកដឹកនាំរបស់កណបក្សមួយនោះ ដែលបានប្រគេនតំណែងឲ្យសម្ដេច ទេព-វង្ស តាំងពីដើមមក ។ មន្ត្រីសង្ឃនៃរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះ កិច្ចការធំៗដែលទាក់ទងនឹងបញ្ហាជាតិ ពុំមានអំណាចសំរេចដោយខ្លួនឯងឡើយ គឺពុំឯករាជ្យឡើយ ។ ត្រង់នេះមានលក្ខណៈខុសគ្នាពីមន្ត្រីសង្ឃនៅប្រទេសថៃ ។ នៅប្រទេសថៃ មានថេរសមាគមជាអំណាចសង្ឃជាន់ខ្ពស់ ដែលមានសមាជិក៩អង្គ សុទ្ធតែជាព្រះសង្ឃមានចំណេះវិជ្ជានិងមានគុណធម៌ខ្ពស់ សំរាប់ចាត់ចែងនិងសម្រេចកិច្ចការធំៗក្នុងព្រះពុទ្ធសាសនា ។ ចំណែកក្រសួងធម្មការ គ្រាន់តែជាលេខាធិការរបស់ថេរសមាគមនោះប៉ុណ្ណោះ ពុំមែនក្រសួងធម្មការដែលជាតំណាងរដ្ឋាភិបាល មកត្រួតលើថេរសមាគមឡើយ គឺក្រសួងធម្មការគ្រាន់តែធ្វើតាមបញ្ជារបស់ថេរសមាគមប៉ុណ្ណោះ ។ ព្រះសង្ឃជាន់ខ្ពស់នៃប្រទេសថៃ ស្ថិតនៅក្នុងភាពឯករាជ្យ ពុំបំរើគណនយោបាយណាមួយឡើយ ដែលមានលក្ខណៈខុសគ្នាពីមន្ត្រីសង្ឃនៅប្រទេសកម្ពុជា ។

៥- <u>អំពីការរឹបយកដីប្រជាពលរដ្ឋ របស់អ្នកកាន់អំណាចខ្មែរ</u> ៖

បន្ទាប់ពីខ្មែរក្រហមត្រូវដួលរលំ អ្នកធំអ្នកមានអំណាចបានចាប់យកដីប្រជាពលរដ្ឋគ្រប់ទីកន្លែង ហើយឃុបឃិតជាមួយរដ្ឋអំណាចមូលដ្ឋានឲ្យដាក់ឈ្មោះខ្លួន ។ មួយផ្នែកទៀត អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភនិងឈ្មួញកណ្ដាល បានទៅបញ្ចុះបញ្ចូលប្រជាពលរដ្ឋក្រីក្រ ដែលមានដីតែបន្តិចបន្តួច ឲ្យលក់ដីឲ្យខ្លួន ដោយឲ្យតម្លៃយ៉ាងថោក ហើយយកទៅលក់យកចំណេញយ៉ាងច្រើន ។ ដោយទំរើបែបនេះ ប្រជាពលរដ្ឋស្រុកស្រែចំការកាន់តែក្រទៅៗ ដោយខ្វះដីស្រែចំការធ្វើ ។ បើរដ្ឋអំណាចនៅតែបណ្ដោយឲ្យជនទុច្ចរិតរំលោភយកដីប្រជាពលរដ្ឋយ៉ាងនេះតទៅទៀត ហើយមិនដោះស្រាយឲ្យប្រជាពលរដ្ឋមានដីស្រែចំការធ្វើទេ ទៅមុខទៀតនឹងមានវិបត្តិក្នុងសង្គមយ៉ាងធំពុំខាន ដោយភាពក្រីក្រនិងភាពអយុត្តិធម៌ក្នុងសង្គមនេះ ។៚